**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍

**សភាស៊ើបសួរ**

សំណុំរឿងលេខ ៣០៧
ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ២០១៦

**សាលដីកា**

លេខ ៣៩ក្រVIអប
ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៦

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍

សភាស៊ើបសួរបង្កើតឡើងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ និងច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកកិច្ចពិភាក្សាដេញដោលជាអសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយមានសមាសភាពចូលរួមដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ប្រធានក្រុមប្រឹក្សា
ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងសភាស៊ើបសួរលេខ ៣០៧ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ២០១៦ ដែលមាន ៖

-ជនត្រូវចោទឈ្មោះ [redacted] សំអុល ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ ជាងផ្សារដែក ទីកន្លែងកំណើតភូមិពាក់បង្អោង ឃុំត្រពាំងធ ស្រុកត្រាំកក់ ខេត្តតាកែវ និងអាស័យដ្ឋានបច្ចុប្បន្ននៅ[redacted]ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រព





Scanned by CamScanner

ឈ្មោះ [redacted] មានកូន០១នាក់ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted](រ) ជានីតិជន។

មានមេធាវីឈ្មោះ [redacted] លានី ការពារសិទ្ធិឲ្យជនត្រូវចោទ ។

**ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទ: ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចបន្ទប់ជួល ភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

**-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ** [redacted] ណែម ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ មន្ត្រីរាជការ មានទីលំនៅបច្ចុប្បន្នផ្ទះជួល ផ្លូវលេខ៧១K ភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted](រ) ។

## អង្គហេតុដាក់ឲ្យស្ថិតក្រោមការពិនិត្យមានដូចតទៅ

កាលពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល៦ល្ងាច ជនរងគ្រោះឈ្មោះ [redacted] ណែម បានយកម៉ូតូ០១គ្រឿង ម៉ាកហុងដា C១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០០៨ ផ្លាកលេខស្វាយរៀង 1B-៩០៧៥ មកទុកមុខបន្ទប់ជួល ស្ថិតនៅភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ហើយចូលក្នុងបន្ទប់ដេក ស្រាប់តែម៉ោងប្រហែល២ទៀបភ្លឺ ជនសង្ស័យឈ្មោះ [redacted] សុធី ហៅ តឿ និងឈ្មោះ ពៅ បានធ្វើសកម្មភាពលួចម៉ូតូរបស់ខ្លួនយកទៅលក់ឲ្យឈ្មោះ [redacted] **សំអុល** ក្នុងតម្លៃ **១៥០(មួយរយហាសិប)ដុល្លាអាមេរិក** ហើយឈ្មោះ [redacted] សុធី ហៅ តឿ និងឈ្មោះ ពៅ ចែកលុយគ្នាបានម្នាក់ **៧៥(ចិតសិបប្រាំ)ដុល្លាអាមេរិក** ក្រោយពីជនរងគ្រោះដាក់ពាក្យបណ្ដឹងរួចកម្លាំងរាជអាវុធហត្ថធ្វើការស្រាវជ្រាវឃាត់ខ្លួនឈ្មោះ [redacted] សុធី ហៅ តឿ និងឈ្មោះ [redacted] **សំអុល** នៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១៦ កសាងសំណុំរឿងបញ្ជូនមកអយ្យការសាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមនីតិវិធី ចំណែកឈ្មោះ ពៅ បានគេចខ្លួន។

-បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] **សំអុល** បានឆ្លើយនៅចៅក្រមស៊ើបសួរថា: កន្លងមកខ្លួនធ្លាប់បានទិញម៉ូតូចំនួនពីរគ្រឿងពីឈ្មោះ [redacted] សុធី ហៅ តឿ ដោយម៉ូតូម៉ាក



Scanned by CamScanner

ស្វេព គ្មានផ្លាកលេខ ទិញក្នុងតម្លៃ ៧០(ចិតសិប)ដុល្លាអាមេរិក ហើយមួយទៀតម៉ាកគុប ទិញក្នុងតម្លៃ ១២០(មួយរយម្ភៃ)ដុល្លាអាមេរិក ពុំមានផ្លាកលេខ តែមានកាតគ្រីត្រឹមត្រូវ ដោយម៉ូតូគុបនេះក៏នៅប្រើប្រាស់អូសរ៉ឺម៉ករាល់ថ្ងៃ ចំណែកម៉ូតូស្វេព ខ្លួនឲ្យក្មួយនៅស្រុកជិះរាល់ថ្ងៃ ហើយនៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៦ ឈ្មោះ តឿ បានយកម៉ូតូម៉ាកសង់ ពុំមានផ្លាកលេខមកបញ្ចាំខ្លួនក្នុងតម្លៃ ១៥០(មួយរយហាសិប)ដុល្លាអាមេរិក បានមួយអាទិត្យក៏ឈ្មោះ តឿ និងឈ្មោះ ពៅ មកលូសយកម៉ូតូនេះទៅវិញ ដោយឲ្យប្រាក់ចំណេញមកខ្លួន ២០(ម្ភៃ)ដុល្លាអាមេរិក ។ ឈ្មោះ តឿ និងឈ្មោះ ពៅ ជួលបន្ទប់នៅជិតខ្លួនដែរ ហើយស្គាល់គ្នាដោយពុំបានដឹងថាឈ្មោះ តឿ និងឈ្មោះ ពៅ ជាចោរនោះទេ បើខ្លួនដឹងខ្លួនមិនរកស៊ីជាមួយដែរ ។ នៅពេលនេះខ្លួនសុំឲ្យតុលាការមេត្តាជួយសម្រាលទោសឲ្យខ្លួនផង ពីព្រោះខ្លួនដឹងកំហុសហើយ។

-បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] សុធី បានឆ្លើយនៅចៅក្រមស៊ើបសួរថា: ចំពោះចម្លើយដែលខ្លួនបានឆ្លើយនៅអាវុធហត្ថកាលពីថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៦ ខ្លួនទទួលស្គាល់ទាំងស្រុង ។ កន្លងមកខ្លួន និងឈ្មោះ ពៅ ស្នាក់នៅស្នាក់នៅពោធិសែនជ័យ ធ្លាប់បានធ្វើសកម្មភាពលួចម៉ូតូរបស់គេមែន ហើយឈ្មោះ ពៅ ជាមេខ្លោង ពេលលក់ម៉ូតូបានចែកលុយគ្នា ខ្លួនទើបធ្វើសកម្មភាពលួចម៉ូតូជាមួយឈ្មោះ ពៅ បានមួយគ្រឿងទេ ដែលយកទៅលក់ឲ្យឈ្មោះ សំអុល ជាអ្នកស្គាល់គ្នា ហើយជួលបន្ទប់ជិតគ្នាទៀត ។ ឈ្មោះ ពៅ ពេលនេះខ្លួនមិនដឹងនៅឯណាទេ ។ នៅពេលនេះ ខ្លួនសុំឲ្យតុលាការជួយបន្ធូរបន្ថយទោសផង ពីព្រោះខ្លួនបានដឹងកំហុសហើយ។

-បានឃើញ ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណែម បានឆ្លើយនៅចៅក្រមស៊ើបសួរថា: ខ្លួននៅតែរក្សាពាក្យបណ្ដឹង ចុះថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៦ និងចម្លើយដែលឆ្លើយនៅសមត្ថកិច្ច កាលពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៦ ទុកនៅដដែល។ នៅថ្ងៃកើតហេតុខ្លួនបានជិះម៉ូតូជូនប្រពន្ធ និងបងថ្លៃទៅកាត់ខោអាវ រួចម៉ោង១៩ ទើបត្រឡប់មកបន្ទប់ជួលវិញ ហើយបានដាក់ម៉ូតូនៅមុខបន្ទប់ជួល ដូចសព្វដង បានចាក់សោរក រួចខ្លួនបានចូលក្នុងបន្ទប់ដើម្បីសំរាក ។ លុះដល់ម៉ោង៥ ព្រឹក នាថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៦ ខ្លួនក្រោកពីសំរាកមកមើលម៉ូតូក៏មិនឃើញ ។ ខ្លួនដើររកម៉ូតូ និងបានសួរអ្នកជិតខាង តែនៅតែរកមិនឃើញរួចខ្លួន



Scanned by CamScanner

ក៏បានដាក់ពាក្យបណ្ដឹងតែម្ដង ។ ខ្លួនពុំបានស្គាល់អ្នកដែលលួចម៉ូតូរបស់ខ្លួនទេ។ ម៉ូតូរបស់ខ្លួន C១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០០៨ ផ្លាកលេខស្វាយរៀង 1B-៩០៧៥ ម៉ូតូនេះខ្លួនទិញតម្លៃ ១៧៥០ដុល្លាទិញនៅទីរួមខេត្តស្វាយរៀង តែឯកសារទិញលក់បានបាត់អស់ហើយ ។ ក្នុងរឿងនេះ ខ្លួនសុំទាមទារសំនងថ្លៃម៉ូតូចំនួន ១០០០(មួយពាន់)ដុល្លាអាមេរិក និងសុំឲ្យតុលាការផ្ដន្ទាទោសជនល្មើសទៅតាមច្បាប់។

-បានឃើញ ដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំលេខ ៩២៧៦(ឃ)ដ.ព.ស ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចខាងក្រោម:

-មិនព្រមដោះលែងជនត្រូវចោទឈ្មោះ [redacted] សំអុល ភេទប្រុស អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ ជាងផ្សារដែក ទីកន្លែងកំណើតភូមិពាក់បង្អោង ឃុំត្រពាំងធ ស្រុកត្រាំកក់ ខេត្តតាកែវ អាស័យដ្ឋានបច្ចុប្បន្នបន្ទប់ជួល [redacted] ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] រ) ជានីតិជន ។

ដែលត្រូវចោទប្រកាន់ពីបទ: ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចមុខបន្ទប់ជួល ភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៦ បទល្មើសដែលមានចែងបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញ របាយការណ៍ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

-បានឃើញ សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

## នាពេលពិភាក្សាដេញដោល

-ជនត្រូវចោទឈ្មោះ [redacted] សំអុល (វត្តមាន)

-មេធាវី [redacted] លានី ការពារសិទ្ធអោយជនត្រូវចោទ (វត្តមាន)

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណែម (អវត្តមាន)



Scanned by CamScanner

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេប

-ជនត្រូវចោទឈ្មោះ [redacted] **សំអុល** បានឆ្លើយថា: ខ្លួនសុំនៅក្រៅឃុំ ដើម្បីបានទៅជួបជុំប្រពន្ធកូនវិញ ខ្លួនមានមុខរបររកស៊ីផ្សារដែក នៅផ្ដុំតាំងក្រឡាំង ផ្ទះបន្ទប់ជួលជាប់ផ្លូវ ពីមុននៅខេត្តតាកែវ ស្រុកត្រាំកក់ ផ្ទះជួលនៅភូមិព្រៃខ្លា ។ ឈ្មោះ ពៅ ហៅ **តឿ** យកម៉ូតូម៉ាកសង់ ១២៥ មកបញ្ចាំ **១៥០(មួយរយហាសិប)ដុល្លារអាមេរិក** សុំបញ្ចាំមួយអាទិត្យធ្លាប់ស្គាល់ដោយបន្ទប់នៅជិតគ្នា គេយកទៅវិញបានបួនថ្ងៃបានមានរឿង គេសងមកខ្លួន **១៧០(មួយរយចិតសិប)ដុល្លារអាមេរិក** បួនថ្ងៃក្រោយទើបមានរឿង ថ្ងៃក្រោយតុលាការកោះហៅមកឲ្យតាមអាស័យដ្ឋានផ្ទះជួល ខ្លួនបានចូលខ្លួន ។ ក្រោយពីទទួលបញ្ចាំឈ្មោះ តឿ ហៅ ពៅ ខ្លួនមិនដែលទទួលបញ្ចាំផ្សេងទៀតទេ មានតែទិញអាគុប ខ្លួនទទួលបញ្ចាំតែមួយនេះទេ ខ្លួនមិនមានរកស៊ីមុខរបរបញ្ចាំទេ ។ កន្លងមកខ្លួនធ្លាប់ទិញម៉ូតូគុបយកមកធ្វើអូសរ៉ឺម៉កដឹកសព្វថ្ងៃ មានឯកសារ ក្រាតគ្រីត្រឹមត្រូវ ។ សំណូមពរ សុំឲ្យតុលាការជួយឲ្យបាននៅក្រៅឃុំ ។

**តំណាងមហាអយ្យការសន្និដ្ឋានកត់សម្គាល់ប្ដឹងសុំថា:** ពាក្យបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទបានធ្វើឡើងត្រឹមត្រូវតាមមាត្រា ២៦៧ និងមាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌហើយ ។ ជនត្រូវចោទរងការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ ទទួលផលចោរកម្ម មានមុខរបរ ទីលំនៅច្បាស់លាស់ មានគ្រួសារហើយបានសន្យាថា នឹងចូលខ្លួនមកតុលាការនៅពេលណាមានការកោះហៅ ។ ហេតុនេះ គួរក្រុមប្រឹក្សាយកគោលការណ៍សេរីភាពត្រង់មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌមកពិចារណា ។ ប្រសិនក្រុមប្រឹក្សាសម្រេចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ ស្នើសុំឲ្យដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជំនួសវិញ ។

-មេធាវី [redacted] **លានី** ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ [redacted] **សំអុល** បានធ្វើសេចក្ដីសន្និដ្ឋានកត់សម្គាល់ថា៖ ឈ្មោះ [redacted] **សំអុល** ចោទពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តកាលពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។ រឿងនេះកូនក្ដីខ្លួនមិនបានប្រព្រឹត្តទេ ។ ដោយសារកូនក្ដីខ្លួនធ្លាប់ស្គាល់គ្នារស់នៅផ្ទះជួលជិតគ្នា ក៏ទទួលបញ្ចាំម៉ូតូ C125 នោះទៅ ។ មុនថ្ងៃកើតហេតុឈ្មោះ តឿ យកម៉ូតូមកបញ្ចាំ ៤ថ្ងៃក្រោយ ក៏មានបញ្ហាតែម្ដង ។ ម៉ូតូដែលបញ្ចាំត្រូវបានឈ្មោះ តឿ លួសយកវិញហើយ ។ ម្យ៉ាងកូនក្ដីខ្លួនមានទីលំនៅមានមុខរបរពិតប្រាកដ និងមានប្រពន្ធកូន ក្នុងគ្រួសារមានការពឹងផ្អែកទាំងស្រុងមកលើកូនក្ដីខ្លួន ហេតុនេះ ស្នើសុំឲ្យក្រុមប្រឹក្សាសម្រេចឲ្យកូនក្ដីខ្លួនបាននៅក្រៅឃុំតាមច្បាប់



Scanned by CamScanner

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនត្រូវចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវី

-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿង

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់។

**សំអាងហេតុ**

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៦៨៨ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០១៦ របស់មេធាវី **ខំ លានី** ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ [redacted] សំអុល បានធ្វើឡើងក្នុងកំណត់ច្បាប់ ។ ហេតុដូច្នេះ សភាស៊ើបសួរសាលាឧទ្ធរណ៍អាចទទួលពិភាក្សាដេញដោលបាន យោងតាមមាត្រា ២៦៧ មាត្រា ២៧០ និងមាត្រា ២៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-ជនត្រូវចោទឈ្មោះ [redacted] សំអុល ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ **ទទួលផលចោរកម្ម** ត្រង់មាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៦ ហើយជនត្រូវចោទត្រូវបាន ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ សម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំ តាមដីកាសម្រេចលេខ ៨២៧៦(ឃ)ដពស ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១៦ ។

៣-តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការបានកត់សម្គាល់ប្តឹងសុំថា ពាក្យបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារសិទ្ធិឲ្យជនត្រូវចោទបានធ្វើឡើងត្រឹមត្រូវតាមមាត្រា ២៦៧ និងមាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌហើយ ។ ជនត្រូវចោទរងការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ **ទទួលផលចោរកម្ម** មានមុខរបរ ទីលំនៅច្បាស់លាស់ មានគ្រួសារហើយបានសន្យាថា នឹងចូលខ្លួនមកតុលាការនៅពេលណាមានការកោះហៅ ។ ហេតុនេះ គួរក្រុមប្រឹក្សាយកគោលការណ៍សេរីភាពត្រង់មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌមកពិចារណា ។ ប្រសិនក្រុមប្រឹក្សាសម្រេច



Scanned by CamScanner

ដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ ស្នើសុំឲ្យដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជំនួសវិញ ។

៤-តាមសេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] លានី ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ ឯក សំអុល បានកត់សម្គាល់ប្តឹងសុំថា កូនក្តីខ្លួនរងបទចោទមជ្ឈិម មិនមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខសង្គមនោះទេ កិច្ចស៊ើបសួរក៏ជឿនលឿនដែរ កូនក្តីខ្លួនមានទីសំណាក់នៅភូមិព្រែខ្លា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ហើយក៏គ្មានភស្តុតាងអ្វីទៀតដែលត្រូវស្រាវជ្រាវដែរ។ ម៉្យាងវិញទៀត តាមអង្គហេតុ ឈ្មោះ [redacted] សំអុល មិនបានប្រព្រឹត្តល្មើសទេ ។ កូនក្តីខ្លួនបានទទួលបញ្ចាំម៉ូតូសង់១២៥ ក្នុងតម្លៃ **១៥០(មួយរយហាសិប)ដុល្លាអាមេរិក** ក្នុងរយៈពេល ១(មួយ)សប្តាហ៍ ហើយក្រោយមកឈ្មោះ **តឿ** បានមកលួសវិញក្នុងតម្លៃ **១៧០(មួយរយចិត្តសិប)ដុល្លាអាមេរិក**។ រយៈពេល៤(បួន)ថ្ងៃក្រោយ ទើបមានហេតុការណ៍កើតឡើង។ ចំណែកម៉ូតូគុបវិញ កូនក្តីខ្លួនទិញពីម្ចាស់ដើម មានឯកសារត្រឹមត្រូវ ហើយសព្វថ្ងៃរត់រ៉ឺម៉កកង់បី ហើយជនត្រូវចោទបានធានាថា នឹងខ្លួនមកតាមតម្រូវការរបស់តុលាការ។ អាស្រ័យហេតុនេះ សុំឲ្យក្រុមប្រឹក្សាសម្រេចដោះលែងកូនក្តីខ្លួនឈ្មោះ [redacted] សំអុល ឲ្យនៅក្រៅឃុំតាមនីតីវិធី។

៥-ជនត្រូវចោទមានទីលំនៅច្បាស់លាស់ មានមុខរបរពិតប្រាកដ បានសន្យាថានឹងចូលខ្លួនមកតុលាការគ្រប់ពេលដែលតុលាការកោះហៅ មិនបង្កការលំបាកដល់ការស៊ើបសួររបស់តុលាការ បទល្មើសក៏បានបញ្ចប់ដែរ បទចោទជាបទមជ្ឈិម មិនមានភាពស្មុគស្មាញទេ ។ ជនត្រូវចោទត្រូវបានឃុំខ្លួនមានរយៈពេលជិត ៤(បួន)ខែហើយ ។ បើធៀបទៅនឹងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីក្រុមប្រឹក្សាពិចារណា ។ ហេតុនេះ ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំមិនមានការបារម្ភថា ប៉ះពាល់ដល់នីតិវិធីស៊ើបសួររបស់តុលាការទេ។

៦-ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី ត្រូវបានតុលាការកត់ត្រាចម្លើយរួច ។ ការស៊ើបសួរមានភាពជឿនលឿន ។ ហេតុនេះ ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ ជនត្រូវចោទមិនមានឥទ្ធិពលដល់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែរ។

៧-គោលការណ៍សេរីភាពត្រង់មាត្រា ២០៣ ការដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការត្រង់មាត្រា ២២៣ នៃក្រមនីតីវិធីព្រហ្មទណ្ឌ និងសាពចរស្តីពី ការអនុវត្ត



Scanned by CamScanner

បទបញ្ញត្តិដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ០១៣ឃសរ/១៤ ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៤ របស់ចៅក្រមស៊ើបសួរ ហើយយកមកប្រើក្នុងករណីនេះ។

**ហេតុដូចនេះ មិនិត្យរួចសម្រេច** 

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍លេខ ៦៨៨ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០១៦ របស់លោកមេធាវី [redacted] លានី ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ [redacted] សំអុល មុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-សម្រេចដោះលែងជនត្រូវចោទឈ្មោះ [redacted] សំអុល (អត្តសញ្ញាណមាននៅក្នុងសំណុំរឿងស្រាប់) ពីបទ **ទទួលផលចោរកម្ម** ក្រោមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិតាងួន សង្កាត់កាកាប ខ័ណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១៦ ។

៣-សម្រេចដាក់ជនត្រូវចោទឈ្មោះ [redacted] សំអុល ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនូវចំណុចដូចតទៅ:

ក-មិនត្រូវចាកចេញពីព្រះរាជាណាចក្រកម្ពុជា ។

ខ-មិនត្រូវផ្លាស់ប្ដូរលំនៅស្ថានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។

គ-ត្រូវចូលទៅបង្ហាញខ្លួននៅប៉ុស្តិ៍នគរបាលសង្កាត់កាកាប ខ័ណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញរៀងរាល់ថ្ងៃទី ០១ នៃខែនីមួយៗ ។

ឃ-ត្រូវឆ្លើយតបទៅនឹងការកោះហៅរបស់តុលាការ ។

៤-បង្គាប់ឲ្យលោកប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន(ម១) ធ្វើការដោះលែងឈ្មោះ [redacted] សំអុល ចេញពីពន្ធនាគារជាបន្ទាន់ ប្រសិនឈ្មោះនេះមិនត្រូវបានឃុំខ្លួនពីបទល្មើសអ្វីផ្សេងទៀតទេ ។

ក្នុងករណី ជនត្រូវចោទគេចវេះដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរនឹងចាប់ជនត្រូវចោទយកមកឃុំខ្លួនតាមមាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា: [redacted] |

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។

ភ្នំពេញ [illegible] ខែវិច្ឆិកា ឆ្នាំ២០១៦



[redacted]

[redacted]

Scanned by CamScanner